**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតធានាអះអាង

ឈ្មោះ **ជឹម បញ្ញា** ភេទស្រី ដែលកាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០១០៩៨៦១៧៤ អាសយដ្ឋាន ភូមចុងថ្នល់ខាងកើត សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ តួនាទីជា ប្រធានរដ្ឋបាល នៅសហគ្រាស គ្រឹះស្ថាន **ជីន ហ្វេង ដា (ខេមបូឌា) ព្រីនធីង ឯ.ក** ពិតជាបានទទួលការណែនាំពីការរៀបចំលិខិតស្នើសុំព្យួរកិច្ចសន្យាការងារ និងបញ្ជីរាយនាមកម្មករនិយោជិត ពីមន្ត្រីឈ្មោះ **ថេង ស៊ីណាត** ភេទស្រី ដែលមានអត្តលេខការងារ **២៨៤១២០០២៦៤** របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដូចខាងក្រោម៖

១-ការដាក់លិខិតស្នើសុំព្យួរកិច្ចសន្យាការងារតាមទម្រង់ដែលបានកំណត់ ទៅនាយកដ្ឋានអធិការកិច្ចការងារ ដោយភ្ជាប់មកជាមួយនូវ៖

- បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលស្នើសុំព្យួរកិច្ចសន្យាការងារ
- កិច្ចព្រមព្រៀងរវាងកម្មករនិយោជិតជាមួយនិយោជក ចំនួន ៣ ច្បាប់
- វិញ្ញាបនបត្រពាណិជ្ជកម្ម/អាជីវកម្ម (ថតចម្លង) ចំនួន ៣ ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ (ថតចម្លង) ចំនួន ៣ ច្បាប់
- វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន ក្នុង ប.ស.ស. ចំនួន ៣ ច្បាប់

២-ការរៀបចំបញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ៣ ច្បាប់ និងផ្ញើជា Soft Copy តាមទម្រង់ MS Excel មកកាន់ Email: suspension@nea.gov.kh ហើយត្រូវមានទិន្នន័យដូចខាងក្រោម៖

- ឈ្មោះកម្មករនិយោជិត/ភេទ/ថ្ងៃខែឆ្នាំកំណើត/បម្រើការនៅផ្នែក
- លេខប័ណ្ណសមាជិកប.ស.ស/លេខរៀងក្នុងបញ្ជីកម្មករនិយោជិតដែលបានធ្វើបច្ចុប្បន្នភាពមកក្រសួង
- លេខអត្តសញ្ញាណប័ណ្ណ
- លេខទូរស័ព្ទ (ផ្ទាល់ខ្លួន)
- ស្នាមមេដៃស្តាំ

៣-ការបោះត្រាក្រុមហ៊ុននៅគ្រប់ទំព័រនៃបញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារ

៤-ការទទួលខុសត្រូវបង់ជូនកម្មករនិយោជិតនូវប្រាក់ឧបត្ថម្ភ ចំនួន៤៥(ដុល្លារអាម៉េរិក) ក្នុងរយៈពេលព្យួរកិច្ចសន្យាការងារចំនួន៣២ថ្ងៃ (ចាប់ពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤) ក្នុងករណីមិនបានផ្សព្វផ្សាយ និងមិនបានតម្រូវឱ្យកម្មករនិយោជិតផ្តល់លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទ ដែលខ្លួនបានចងក្រងរួច និងផ្តិតស្នាមមេដៃបញ្ជាក់។

៥-ក្រុមហ៊ុនបានប្រាប់កម្មករនិយោជិតឱ្យទិញលេខទូរស័ព្ទ (ករណីគ្មានលេខទូរស័ព្ទ) ហើយនឹងកាត់បញ្ជីឈ្មោះកម្មករនិយោជិតទាំងឡាយណាដែលមិនមានលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទ ចេញពីបញ្ជីឈ្មោះកម្មករនិយោជិតដែលត្រូវស្នើសុំព្យួរកិច្ចសន្យាការងារ។

ខ្ញុំក្នុងនាមនិយោជក បានយល់និងឯកភាពគោរពតាមការណែនាំដូចមានខាងលើ នៅចំពោះមុខអធិការការងារ និងសូមប្តេជ្ញាចិត្តអនុវត្តតាមការណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសូមទទួលខុសត្រូវចំពោះមុខច្បាប់ លើការធានាអះអាងនេះ។

ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣

**តំណាងនិយោជក**
**ស្នាមមេដៃស្តាំ**

**ជឹម បញ្ញា**

**អធិការការងារ**
**ស្នាមមេដៃស្តាំ**

**ថេង ស៊ីណាត**